# ការសម្ភាសន៍របស់បងស្រី លៀត នៅ

កៈ អ្នកសំភាសន៍ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍ លៀត នៅ

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ លៀត នៅ</u>

សង្ខេបៈ បងស្រី លៀត នៅ
គាត់ជាមនុស្សម្នាក់ដែលមានការលំបាកច្រើននៅក្នុងជីវិតរបស់គាត់
តែគាត់នៅតែមានសំណាងច្រើនជាងជីវិតរបស់ម្តាយរបស់គាត់ដោយសារគាត់នៅមានប្តីរបស់គាត់នៅជួយមើលថៃគាត់ហើយរកស៊ីចិញ្ចឹមគាត់។
ហើយកូនស្រីរបស់គាត់បានចេញទៅរកស៊ីឈ្នួលគេនៅប្រទេសថៃហើយបានយកចៅមកអោយគាត់មើល ហើយគាត់បានផ្ញើរលុយមកខ្លះដើម្បីអោយគាត់ចិញ្ចឹមកូនអោយ។
ក្នុងជីវិតរបស់គាត់ គាត់មានការសោកស្តាយច្រើនដោយសារគាត់បានបោះបង់ការសិក្សាហើយគោលបំណងរបស់គាត់ចង់អោយកូនចៅរបស់គាត់ខំប្រឹងរៀនសូត្រដើម្បីពួកគេអាចមានការងារល្អហើយជៀសផុតពីការលំបាកដូចគាត់។ធ្វើឡើងនៅភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២៩ ខែ០៦ ឆ្នាំ២០១៨។

កៈ ជំរាបសួរបង ខ្ញុំឈ្មោះ គង់ ចាន់ណាក់
ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជាដែលគម្រោងនឹងធ្វើឡើងដោយសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិចដែលមានឈ្មោះថាសាកលវិទ្យាល័យ ប៊ី វ៉ាយ យ៉ូ
ដោយសារតែសាកលវិទ្យាល័យមានគោលបំណងចង់ថៃរក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរទុកសំរាប់កូនចៅជំនាន់ក្រោយដើម្បីពួកគេអាចរៀន
ហើយស្គាល់ពីប្រវត្តិ របស់ជីដូនជីតាហើយនឹងឪពុកម្តាយ។
ហើយសំរាប់ការសម្ភាសន៍របស់យើងថ្ងៃនេះ យើងធ្វើនៅ ភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ហើយសំរាប់ការសម្ភាសន៍នេះយើងធ្វើនៅ ថ្ងៃទី២៩ ខែ០៦ ឆ្នាំ២០១៨។ ហើយអញ្ចឹងសំរាប់ការសម្ភាសន៍មួយនឹងយើងនឹងថតជាសំលេង
ហើយនឹងថតជារូបភាព ដើម្បីយើងអាចផ្ញើរទៅកាន់សាកលវិទ្យាល័យ
ដើម្បីសាកលវិទ្យាល័យ
អាចយកសំលេងហើយនឹងរូបភាពរបស់បងស្រីដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹង តើបងស្រីយល់ព្រមអោយយើងយកសំលេង
ហើយនឹងរូបភាពរបស់បងស្រីដាក់នៅ លើវេបសាយរបស់សាកលវិទ្យាល័យទេ បងស្រី?

ខ៖ ចាំ!

ក៖ អញ្ចឹងអរគុណច្រើនបង
ដែលបងស្រីអនុញ្ញាតិអោយខ្ញុំយកសំលេងហើយនឹងរូបភាពរបស់
បងស្រីយកដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យណាបងស្រី។
ហើយអញ្ចឹងដំបូងចង់សួរ បងស្រីមានឈ្មោះអីដែរ បងស្រី?

ខ៖ ខ្ញុំឈ្មោះ លៀត នៅ។

ក៖ លៀត នៅ! បាទ! បាទ!! ហើយអញ្ចឹង តើបងស្រីមានឈ្មោះហៅក្រៅទេ បងស្រី?

ខ៖ អត់មាន។
ក៖ អត់មានទេបងស្រីហ៎! បាទ! បាទ! ហើយអញ្ចឹងសំរាប់បងស្រី
កាលបងស្រីនៅក្មេងៗគេហៅ ឈ្មោះបងស្រីថាម៉េចដែរ បងស្រី?

ខ៖ គេហៅឈ្មោះអញ្ចឹងម៉ង។

ក៖ គេហៅឈ្មោះអញ្ចឹងម៉ងបង! បាទ! បាទ! ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ
បងស្រីមានអាយុប៉ុន្មាន ឆ្នាំហើយ បងស្រី?

ខ៖ អាយុសែសិបមួយឆ្នាំ។

ក៖ បងស្រីអាយុសែសិបមួយឆ្នាំហ៎! បាទ! បាទ!! ហើយសំរាប់បងស្រី បងស្រីនៅចាំថា
បងស្រី កើតនៅឆ្នាំណាទេ?

ខ៖ កើតឆ្នាំមមី។

ក៖ កើតឆ្នាំមមីឆ្នាំខ្មែរន៎បងន៎! អញ្ចឹងបងស្រីកើតឆ្នាំខ្មែរឆ្នាំមមី។
ហើយអញ្ចឹងកើតឆ្នាំមួយប្រាំបួនរយ ប៉ុន្មានអត់ដឹងទេ?

ខ៖ អត់ដឹង ខ្ញុំអត់ដឹងទេ។

ក៖ អាយុសែសិបមួយបងអេស៎!
អញ្ចឹងបងស្រីកើតឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំពីរបង។ ហើយអញ្ចឹងសំរាប់បងស្រី
តើបងស្រីកើតនៅកន្លែងណាដែរ បងស្រី?

ខ៖ ខ្ញុំកើតនៅនឹង នៅភូមិក្បាលអូរ។

ក៖ ឃុំអីគេដែរ បងស្រី?

ខ៖ ឃុំដំរិល។

ក៖ ស្រុក?

ខ៖ ស្រុកអូររាំងឳ ខេត្តត្បូងឃ្មុំ។

ក៖ បាទ! បាទ! អរគុណច្រើនបងស្រី!
ហើយអញ្ចឹងសំរាប់បងស្រីមានបងប្អូនចំនួនប៉ុន្មាននាក់ដែរ បងស្រី?

ខ៖ បងប្អូនពីរនាក់។

ក៖ មានតែពីរនាក់ទេន៎!

ខ៖ ចា៎! ស្រីមួយ ប្រុសមួយ។

ក៖ អូ! បងប្អូនស្រីមួយប្រុសមួយន៎បងន៎! ហើយអញ្ចឹងបងស្រីកូនទីប៉ុន្មានដែរ បងស្រី?

ខ៖ កូនទីពីរ។

ក៖ អូ! បងប្អូនពៅ។ ហើយអញ្ចឹងបងស្រីជួយរៀបឈ្មោះបងប្អូនរបស់បងស្រីបានទេ?

ខ៖ បងរបស់ខ្ញុំឈ្មោះសៅ ហើយមកខ្ញុំឈ្មោះនៅ។

ក៖ ហើយអញ្ចឹងសំរាប់បងស្រីពេលនៅក្មេងៗ
បងស្រីចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់បងស្រី?

ខ៖ ខ្ញុំបែកគ្នា
បងរបស់ខ្ញុំគាត់ទៅនៅជាមួយឪពុករបស់ខ្ញុំគាត់បែកគ្នាតាំងពីជំនាន់ប៉ុលពតណោះ
គាត់ទៅនៅនឹងទៅយើងអត់សូវបាននៅជាមួយគ្នា បានធ្វើអ្វីមួយជាមួយបងប្អូនចឹងណា។

ក៖ ប៉ុន្តែពេលនៅពីក្មេងនៅជាមួយគ្នាដែលតាបងស្រី?

ខ៖ ខ្ញុំអត់បានដឹង ពេលខ្ញុំដឹងឡើងបែកគ្នាអញ្ចឹងម៉ង។

ក៖ អញ្ចឹងន៎ អូ! អត់ដែលបាននៅជាមួយបងប្អូនទេន៎បងន៎! ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ
តើគាត់រស់នៅកន្លែងណាដែរ បងស្រី?

ខ៖ សព្វនេះបងប្រុសរបស់ខ្ញុំគាត់នៅស្រុកថៃ ប៉ុន្តែគាត់ទាក់ទងមកខ្ញុំរាល់ថ្ងៃដែរ។

ក៖ នៅថៃឯណោះ! គាត់ធ្វើការអីដែរ បងស្រី?

ខ៖ គាត់កាច់ផ្លែម្នាស់។

ក៖ អូ! កាច់ផ្លែម្នាស់!

ខ៖ ចាំ! កាច់ម្នាស់ គាត់ស៊ីឈ្នួលគេទេណា គេអោយ
គាត់មិនមែនមានការងារអីរបស់គាត់តែម្តងទេ។

ក៖ គាត់ស៊ីឈ្នួលកាច់ម្នាស់អោយគេ។

ខ៖ ចាំ! ហ្នឹងហើយ!

ក៖ ហើយអញ្ចឹងសំរាប់ម្តាយរបស់បងស្រីគាត់ឈ្មោះអ្វីដែរ បងស្រី?

ខ៖ ម្តាយរបស់ខ្ញុំគាត់ឈ្មោះ គង់ ទី។

ក៖ គង់ ទី! ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះម្តាយរបស់បងស្រីមានអាយុប៉ុន្មានឆ្នាំហើយ
បងស្រី?

ខ៖ ម្តាយរបស់ខ្ញុំមានអាយុចិតសិបពីរឆ្នាំ។

ក៖ ចិតសិបពីរឆ្នាំ! ហើយអញ្ចឹង គាត់រស់នៅរាល់ថ្ងៃដែរ បងស្រី?

ខ៖ គាត់រស់នៅរាល់ថ្ងៃ ខ្ញុំនៅបន្ទុកជាមួយគាត់ ចិញ្ចឹមគាត់។

ក៖ អូ! បងស្រីចិញ្ចឹមគាត់រាល់ថ្ងៃន់បងន់! អញ្ចឹង
តើម្តាយរបស់បងស្រីគាត់កើតនៅពេលណា បងស្រីមាននៅចាំទេ?

ខ៖ ខ្ញុំមិនចាំគាត់ដែរនឹងណា ចាំ!
អត់ចាំទេអត់ដឹងគាត់កើតនៅពេលណាខ្ញុំមិនបានដឹងដែរ។

ក៖ អញ្ចឹងសំរាប់គាត់ គាត់កើតឆ្នាំអីឆ្នាំខ្មែរបងស្រី?

ខ៖ ឆ្នាំខ្មែរគាត់ឆ្នាំជូត។

ក៖ អូ! គាត់កើតឆ្នាំជូត បាទ! បាទ!! គាត់កើតឆ្នាំជូត។

ខ៖ ឆ្នាំជូតបើរាល់អាយុចិតសិបពីរហើយ។

ក៖ បាទ! បាទ!! ហ្នឹងហើយ!
ហើយអញ្ចឹងសំរាប់ម្តាយរបស់បងស្រីគាត់កើតនៅកន្លែងណាដែរ បងស្រី?

ខ៖ គាត់កើតនៅភូមិនឹងដែរ គាត់កើតនៅភូមិក្បាលអូរនឹងដែរ។

ក៖ នៅភូមិក្បាលអូរដែរ ន៎បងន៎!
ហើយកាលគាត់នៅក្មេងៗគាត់ប្រកបមុខរបរអ្វីដែរចិញ្ចឹមជីវិត បងស្រី?

ខ៖ គាត់ប្រកបមុខរបរ កាលដែលខ្ញុំដឹងគាត់ដើរតែស៊ីឈ្នួលគេយកមកចិញ្ចឹមកូន
គាត់ពិបាកគ្មានប្ដីឯណារស់ស៊ីចិញ្ចឹម ប្ដីជំនាន់អាពត
គាត់កើតខ្ញុំបានកន្លះខែគេកៀរយកទៅ ដល់ពេលដែលគេកៀរ
យកទៅប្ដីរបស់គាត់រត់គេខ្លួនពីប្រពន្ធរបស់គាត់បែកទៅបាត់ទៅណា។
គាត់បែកទៅបាត់ទៅ គាត់រកស៊ី ស៊ីឈ្នួលគេចឹងទៅណាមកចិញ្ចឹមកូន
គាត់អត់មានប្ដីណារកស៊ីជួយចិញ្ចឹមកូនដូចគេទេ
ហើយគាត់បែកគ្នាតាំងពីជំនាន់ប៉ុលពតរហូតមកដល់ឥលូវទៅណា
គាត់អត់ជួបគាត់ដល់ឥលូវទៅណា។

ក៖ ហើយអញ្ចឹងសំរាប់ឪពុករបស់បងស្រីគាត់មានឈ្មោះអ្វីដែរ បងស្រី?

ខ៖ គាត់ឈ្មោះស្អីលៀតទេអ៊ុំស្រី ឪពុកគាត់ឈ្មោះឡុង លៀត។

ក៖ អត់ទេ ឪពុករបស់បងស្រីតែម្ដង?

ខ៖ ឪពុករបស់ខ្ញុំម៉ងឈ្មោះលៀត។

ក៖ ហើយអញ្ចឹងសព្វថ្ងៃនេះឪពុករបស់បងស្រីគាត់មានអាយុប៉ុន្មានហើយ?

ខ៖ គាត់អាយុចិតជាងហើយ។

ក៖ គាត់អាយុចិតជាងហើយ!

ខ៖ ចិតសិបពីរ ចិតសិបបីដែរហើយ គាត់នៅរស់ដែរ។

ក៖ រស់នៅដែរបងហ៎! ហើយអញ្ចឹង តើគាត់កើតនៅពេលណាដែរ បងស្រីមាននៅចាំទេ?

ខ៖ គាត់ប្រហែលជាឆ្នាំនោះដែរ គាត់កើតនៅពេលណាខ្ញុំអត់ដឹងទេ ដឹងតែឆ្នាំគាត់ឆ្នាំជូត
ឬមួយឆ្នាំអី គាត់ប្អូនម្ដាយមួយឆ្នាំ អញ្ចឹងឆ្នាំឆ្លូវ។

ក៖ អញ្ចឹងឪពុករបស់បងស្រីឆ្នាំឆ្លូវ។
ហើយអញ្ចឹងសំរាប់ឪពុករបស់បងស្រីគាត់កើតនៅកន្លែងណាដែរ បងស្រី?

ខ៖ គាត់កើតនៅ ស្រុកកំណើតគាត់នៅខាងចំឡាក់ឯណោះ។

កៈ ខាង ចំឡាក់! ចំឡាក់ នឹងឃុំអីគេដែរ?

ខៈ ឃុំចក។

កៈ ភូមិចំឡាក់ ឃុំចក អានឹងស្រុកកំណើតរបស់ឪពុកបងស្រី។ បាទ! បាទ!!
ហើយអញ្ចឹងសព្វថ្ងៃនេះគាត់នៅរស់ ឬមួយគាត់បានស្លាប់ហើយ បងស្រី?

ខៈ គាត់នៅរស់។

កៈ ហើយអញ្ចឹង តើគាត់រស់នៅឯណាដែរ បងស្រី?

ខៈ រាល់ថ្ងៃនឹងគាត់មានប្រពន្ធនៅឈូក។

កៈ ឃុំណាដែរនឹង បងស្រី?

ខៈ ទេមិនដឹងជាឃុំណាទេ ឈូកនឹង។

កៈ នៅផ្គុំណាដែរ បងស្រី?

ខៈ នៅខាងជើងសួងនឹង ទៅពីសួងទៅ។

កៈ អូ! នៅខាងជើងសួងហ៎! បាទ! បាទ!!
ហើយអញ្ចឹងសំរាប់ឪពុករបស់បងស្រីកាលគាត់នៅក្មេងៗ គាត់ប្រកបមុខរបរអ្វីដែរ បងស្រី?

ខៈ កាលគាត់នៅក្មេងៗគាត់ធ្វើស្រែ ធ្វើចំការចឹងដែលនឹង។

កៈ អញ្ចឹងហ៎! ធ្វើស្រែ ធ្វើចំការ បងហ៎!
ហើយអញ្ចឹងឪពុករបស់បងស្រីគាត់មានចរិតបែបណាដែរ បងស្រី?

ខៈ ចរិតគាត់ធម្មតា ស្លូតបូតធម្មតាចឹងទៅ
គ្រាន់តែគាត់បែកពីម្តាយរបស់ខ្ញុំទៅយកប្រពន្ធទៀតចឹង ប៉ុននឹង។

កៈ តែសំរាប់គាត់ បងស្រីដែលទាក់ទងជាមួយគាត់ទេរាល់ថ្ងៃនឹង?

ខៈ ដែល គាត់ឧស្សាហ៍មកខ្ញុំណាស់ តាមលេខតាមទូរស័ព្ទអី
ខ្ញុំតែទៅនិយាយលេងជាមួយគាត់ដែរតើ គាត់មក មួយឆ្នាំអីជួនកាលគាត់មកពីដង
ជួនកាលគាត់មកតែម្តងចឹងទៅ។

កៈ បាទ! បាទ!! តែគាត់នៅទាក់ទងយើងរាល់ឆ្នាំដែរ។

ខ៖ ហើយខ្ញុំដែលទៅលេងជាមួយគាត់បានម្ដងដែរ តាំងពីខ្ញុំដឹងក្ដីដល់ប៉ុននឹងធ្លាប់ទៅលេងគាត់បានម្ដងហើយ តែគាត់ឧស្សាហ៍មក។

ក៖ គាត់ឧស្សាហ៍មក! ហើយអញ្ចឹងសំរាប់ឪពុកម្ដាយរបស់បងស្រីធ្លាប់ប្រាប់បងស្រីពីជីវិតរបស់គាត់កាលគាត់នៅក្មេងៗទេ បងស្រី?

ខ៖ បើម៉ែរបស់ខ្ញុំគាត់ធ្លាប់និយាយប្រវត្តិគាត់ថា ជំនាន់ប៉ុលពតគាត់ពិបាកស្ទូទ្រាំចឹងណា គាត់គ្មានប្ដីគ្មានអីចិញ្ចឹមនឹងគេចឹង កៀរទៅគាត់ពិបាកណាស់រត់ទៅ ពិបាកពិបិនគាត់ម្នាក់ឯងហើយកូនចឹង គាត់កូនខ្ញុំនៅតូច ហើយគាត់និយាយហើយទឹកភ្នែកគាត់ថាចឹង។ ជំនាន់ប៉ុលពតខ្ញុំមិនតាំងដឹងផង គាត់ថាខ្ញុំកើតបានកន្លះខែគាត់បីខ្ញុំយកទៅ ដើរជើងទទេគាត់ដល់ស្អីណាឯណោះ ដឹងឯណាខ្ញុំមិនស្គាល់ផងលឺតែគាត់និយាយដែរ ដឹងឯណាអ៊ីជិន ឯណានឹង តាំងក្រសាំង តាំងក្រសាវណានឹង គាត់ថាបីខ្ញុំឡើងទាស់។

ក៖ ហើយអញ្ចឹងសំរាប់បងស្រីមាននៅចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់បងស្រីទេ?

ខ៖ ជីដូនជីតាខាងម៉ែរបស់ខ្ញុំគាត់ឈ្មោះ តា គង់ យាយ ជិន ខាងម្ដាយរបស់ខ្ញុំ ហើយបើខាងឪពុករបស់ខ្ញុំគាត់ឈ្មោះ តា ឡុង យាយ ឆាន។

ក៖ ហើយអញ្ចឹងសំរាប់ជីដូនជីតាខាងម្ដាយរបស់បងស្រីគាត់កើតនៅពេលណា បងស្រីមានដឹងទេ?

ខ៖ ខ្ញុំអត់ចាំ ខ្ញុំអត់ដឹងទេព្រោះអីខ្ញុំអត់បានឃើញមុខគាត់ដែរ។

ក៖ អញ្ចឹងហ៎! អត់បានឃើញមុខគាត់ទេ!

ខ៖ ខ្ញុំបើជីដូនជីតាខាងម្ដាយរបស់ខ្ញុំ ខ្ញុំទាន់ខ្មោចយាយរបស់ខ្ញុំយាយជិនខ្ញុំទាន់ តែក្រៅពីនឹងខ្ញុំអត់ឃើញទេ។

ក៖ អញ្ចឹងជួបជាមួយយាយដែរ។

ខ៖ ចា៎! បានជួបឃើញមុខគាត់ចំណាំគាត់ទុកក្នុងចិត្តដល់ឥលូវនឹង តែបើតាខ្ញុំអត់បានចាំទេ។

ក៖ ហើយអញ្ចឹងសំរាប់ពួកគាត់កើតនៅកន្លែងណា បងស្រីដឹងទេ?

ខ៖ ខ្ញុំអត់បានដឹងថាពួកគាត់កើតនៅកន្លែងណាទេ។

កៈ ហើយអញ្ជឹងសំរាប់យាយដែលបងបានទាន់នឹង តើគាត់បានស្លាប់ពេលណាដែរ បងស្រី?

ខៈ គាត់ស្លាប់អាយុចិតសិបបួនឆ្នាំយាយរបស់ខ្ញុំ។ ខ្ញុំទាន់យាយរបស់ខ្ញុំគាត់ស្លាប់អាយុចិតសិបបួនឆ្នាំតែពីនោះមកដល់ឥលូវមិនដឹងជាប៉ុន្មានឆ្នាំទេ ខ្ញុំអត់បានដឹងទេ។

កៈ ហើយអញ្ជឹងពេលដែលយាយរបស់បងស្រីស្លាប់នឹង តើបងស្រីអាយុប្រហែលជាប៉ុន្មានឆ្នាំដែរ?

ខៈ ខ្ញុំមិនដឹងជាអាយុប៉ុន្មានឆ្នាំទេ ខ្ញុំនៅតូចសោះនឹង។

កៈ នៅតូចទេបងស្រី! បាទ! បាទ!!

ខៈ ប្រហែលជាប្រាំបី ប្រាំបួនឆ្នាំយ៉ាង ប៉ុន្តែខ្ញុំចាំថាខ្ញុំបានច្របាច់ដៃប្របាច់អីលើគាត់នោមដែរតើ ចាំអត់ភ្លេចទេ ប្រហែលប្រាំបួនឆ្នាំអីយ៉ាង។

កៈ
ហើយអញ្ជឹងបងស្រីធ្លាប់មានអនុស្សាវរីយ៍អីល្អៗជាមួយជីដូនជីតាខាងម្តាយរបស់បងស្រីទេ? មានធ្លាប់ធ្វើអីអោយគាត់សប្បាយចិត្ត?

ខៈ ខ្ញុំធ្លាប់តែថា គាត់ហៅខ្ញុំថាអោយលើកគាត់ទៅនោមចឹង ខ្ញុំធ្លាប់ទៅលើគាត់ចឹងទៅណា រួចទៅគាត់ស្រែកគាត់ពិបាក ធ្លាប់ដឹងត្រង់នឹង។

កៈ គាត់ឈឺ!
ខៈ ចា៎! គាត់ឈឺ គាត់ឈឺដេកនឹងកន្ទេល ធ្លាប់គាត់ថា លើកអញទៅបត់ជើងចឹងទៅ ទៅលើកគាត់ទាញពីរបីនាក់បងប្អូនជីដូនមួយ ធ្លាប់ដឹងតែប៉ុននឹងទេ បើថាពីនោះមកទៀតអត់ដឹងទេ។

កៈ ហើយអញ្ជឹងសំរាប់ជីដូនជីតាខាងឪពុករបស់បងស្រីគាត់មានឈ្មោះអ្វីដែរ បងស្រី?

ខៈ ឈ្មោះតាឡុង យាយ ឆាន។

កៈ ឈ្មោះតា ឡុង យាយ ឆាន! តើគាត់កើតពេលណា បងស្រីមានដឹងទេ?

ខៈ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំអត់បានឃើញមុខគាត់សោះ។

កៈ ហើយអញ្ជឹងគាត់កើតនៅកន្លែងណាអត់ដឹងទេបងស្រី?

ខ៖ អត់ដឹងគាត់កើតនៅកន្លែងណាដែរ ប៉ុន្តែដឹងតែថាឪពុករបស់ខ្ញុំគាត់មានស្រុកកំណើតនៅនោះ នៅចំឡាក់នឹង ប្រហែលជាគាត់កើតនៅនោះដែរក៏មិនដឹង។

ក៖ អញ្ចឹងប្រហែលជីដូនជីតាកើតនៅនឹងដែរ។ ហើយអញ្ចឹងបងស្រីអត់ដែលជួបជាមួយជីដូនជីតាខាងឪពុករបស់បងស្រីសោះតែម្ដង?

ខ៖ អត់ដែលសោះ អត់ដែលឃើញទេ លឺតែឈ្មោះទេ។

ក៖ អញ្ចឹងមានន័យថាពេលដែលបងស្រីកើតមកគាត់ស្លាប់អស់ហើយ។

ខ៖ ដំណើរអញ្ចឹងហើយមើលទៅ ខ្ញុំនៅតូចមិនទាន់ដឹងក្ដីក៏មិនដឹង។

ក៖ ហើយអញ្ចឹង សំរាប់ក្រុមគ្រួសាររបស់បងស្រីរស់នៅក្នុងខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ បងស្រី?

ខ៖ ខេត្តនឹងហ៎! នៅតាំងពីខ្ញុំដឹងក្ដីមក តាំងពីខ្ញុំដឹងក្ដីមករស់នៅនឹងរហូតម៉ង។

ក៖ នៅនឹងរហូតម៉ងបងស្រី! ហ្នឹងហើយ! ហ្នឹងហើយ!! ហើយអញ្ចឹងបងស្រីមានដូចជាសាច់ញាតិរស់នៅក្រៅប្រទេសខ្មែរយើងទេ បងស្រី?

ខ៖ អត់ដែលមានសោះ។

ក៖ អត់ដែលមានទេ!

ខ៖ បើសាច់ញាតិដូចជា សាច់ញាតិក្មួយ បងប្អូនជីដូនមួយអីចឹងណា មានក្មួយរបស់ខ្ញុំពីរនាក់ទៅនៅប្រទេសជប៉ុន។

ក៖ ទៅនៅប្រទេសជប៉ុនហ៎?

ខ៖ ចា៎! ខ្ញុំជូនវាទៅឡើងយន្ដហោះថ្ងៃមុនដែរ ពីរបីខែមុននឹងណា។

ក៖ ទើបតែនឹងទៅដែរ។

ខ៖ ចា៎! ទើបនឹងទៅទេ។

ក៖ ទៅនៅនឹងម៉ង ឬមួយទៅរៀនដែរ?

ខ៖ ទៅស៊ីឈ្នួលគេ ទៅធ្វើការស៊ីឈ្នួលគេយកលុយមកចិញ្ចឹមគ្រួសារ ចិញ្ចឹមម៉ែឪនៅនឹងផ្ទះ។

កៈ ហើយអញ្ចឹងសំរាប់ស្វាមីរបស់បងស្រីគាត់មានឈ្មោះអ្វីដែរ បងស្រី?

ខៈ គាត់ឈ្មោះ ជឹម នឿន។

កៈ ហើយអញ្ចឹង សំរាប់បងស្រីបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅពេលណាដែរ បងស្រីមាននៅចាំទេ?

ខៈ ខ្ញុំអត់បានរៀបអាពាហ៍ពិពាហ៍ទេខ្ញុំយកគ្នាតែម្តង អត់ដឹងថាយកពេលណាទេ យកគ្នាតែម្តង។

កៈ តែមានដូចជាសែនព្រេនអីដែរតាបងស្រី?

ខៈ សែន គ្ររកអីសែនមិនបាន ពិបាកពេក យើងចេះតែសែនអោយបានយកគ្នាទៅបានកូនមួយគំនរទៅ។

កៈ ហើយពេលដែលបងស្រីសែនព្រេនជាមួយគាត់នឹង តើបងស្រីមានអាយុប្រហែលប៉ុន្មានឆ្នាំហើយ បងស្រី?

ខៈ ខ្ញុំអាយុដប់ប្រាំបួនឆ្នាំ។

កៈ បងស្រីអាយុដប់ប្រាំបួនឆ្នាំ! ហើយពេលសែនព្រេននឹង តើនរណាគេអ្នកជួយរៀបចំអោយដែរ ឪពុកម្តាយ ឬក៏ខ្លួនឯងទេ?

ខៈ ម្តាយរបស់ខ្ញុំ ពូរបស់ខ្ញុំ គាត់អ្នកគិតគូរអោយ។

កៈ អូ! ម្តាយរបស់បងស្រី!

ខៈ ចា៎! តែឥលូវពូរបស់ខ្ញុំគាត់ខូចហើយ។

កៈ បាទ!

ខៈ ឪពុករបស់ខ្ញុំអត់ដឹងទេ។

កៈ បាទ! ឪពុកអត់ដឹងទេ ដោយសារគាត់មានប្រពន្ធមួយផ្សេង។ ហើយពេលសែនព្រេននឹងដូចអត់មានជាជំនួនអីទេ បងស្រី?

ខៈ គ្មានទេ គ្មានជំនួនអីទេ សែនដូចថាសែនក្បាលមាន់។

កៈ ហើយអញ្ចឹងសំរាប់បងស្រីហើយនឹងប្តីរបស់បងស្រីបានជួបគ្នាដំបូងនៅពេលណាដែរ បងស្រី?

ខ៖ ជួបគ្នាដំបូងខ្ញុំវាភ្លេងដែរនែ៎! ជួបគ្នាដំបូងខ្ញុំទៅស៊ីឈ្នួលគេនៅឈូក
ទៅបេះសណ្តែកសៀង។

ក៖ ទៅជួបគ្នានៅនឹង គាត់ទៅដែរ?

ខ៖ គាត់ទៅដែរ។

ក៖ គាត់ទៅស៊ីឈ្នួលគេដែរ?

ខ៖ គាត់ទៅស៊ីឈ្នួលគេដែរ ដូចថាយើងទៅមិនទៅដេកផ្ទះ ដូចថាយើងស៊ីឈ្នួលផ្ទះនឹង
ទៅដេកផ្ទះនឹង ដេកជាមួយគ្នាផ្ទះនឹងចឹងទៅ។

ក៖
ហើយអញ្ចឹងសំរាប់បងស្រីហើយនឹងបងប្រុសនឹងចាប់ដៃគ្នានឹងមានកូនចំនួនប៉ុន្មាននាក់ដែ
រ បងស្រី?

ខ៖ កូនពីរនាក់ ស្រីមួយ ប្រុសមួយ។

ក៖ ស្រីមួយ ប្រុសមួយ ន៎បងន៎! ហើយកូនទាំងពីរនាក់នឹងមានឈ្មោះអ្វីខ្លះដែរ បងស្រី?

ខ៖ ឈ្មោះ នឿន សុជា ស្រី ហើយមួយទៀតនឹងឈ្មោះ នឿន ផានិត ប្រុស ហៅក្រៅហៅ
ម៉ាប់។

ក៖ ហើយអញ្ចឹងរាល់ថ្ងៃនឹងកូនទាំងពីរនាក់នឹងមានអាយុប៉ុន្មានឆ្នាំហើយ បងស្រី?

ខ៖ កូនបងនឹងអាយុម្ភៃឆ្នាំហើយ ហើយកូនពៅប្រុសនឹងអាយុដប់បីឆ្នាំ។

ក៖ ហើយអញ្ចឹងសំរាប់កូនរបស់បងស្រីទាំងពីរមានអ្នករៀបការហើយនៅ
ឬមួយក៏នៅទាំងពីរ?

ខ៖ មានមួយហើយកូនបងស្រីនឹង។

ក៖ រៀបការហើយ?

ខ៖ ចា៎! រៀបការហើយ នៅអាក្រោយ។

ក៖ ហើយកូនស្រីនឹងរៀបការបានប៉ុន្មានឆ្នាំហើយ បងស្រី?

ខ៖ រៀបការប្រាំមួយឆ្នាំហើយ។

ក៖ រៀបការប្រាំមួយឆ្នាំហើយ! ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះបងស្រីមានចៅហើយនៅទេ?

ខ៖ មានចៅមួយ ចៅស្រីម៉ែរបស់វាទៅប្រទេសថៃ។

ក៖ កូនស្រីបងទៅថៃហើយចុះ?

ខ៖ ចា៎! ទៅស៊ីឈ្នួលនៅថៃ តែវាអត់រស់នៅក្នុងបន្ទុកជាមួយខ្ញុំទេ វាទៅនៅខាងប្តី ដល់ពេលវាទៅនៅខាងប្តីនឹង ដល់ពេលកូនគ្មានពីណាយក វាយកមកផ្ញើរនឹងខ្ញុំ។ គេមិនមែនទៅរកស៊ីមកចិញ្ចឹមខ្ញុំទេ គេចិញ្ចឹមជីវិតក្រុមគ្រួសារប្តីប្រពន្ធគេណា។ ចា៎! គេគ្រាន់តែថាអោយផ្តល់មកកូនគេចាយចឹងទៅណា តែជួយយកទៅអោយតែគ្នាទៅរកលុយអោយបានទៅ បើយើងមិនយកទេគ្នាវាគ្មានម៉ែឪណាយក មានតែខ្ញុំនឹងហើយ។

ក៖ ហើយប្តីគាត់ទៅធ្វើការនៅឯណាវិញ?

ខ៖ ប្តីរបស់ខ្ញុំគាត់ទៅស៊ីឈ្នួលគេនៅកំពង់ធំ។

ក៖ អត់ទេ ប្តីរបស់កូនស្រីរបស់បងស្រីនោះណា?

ខ៖ ប្តីទៅថៃជាមួយគ្នា។

ក៖ អូ! ទៅទាំងពីរនាក់ប្តីប្រពន្ធ។

ខ៖ ទៅទាំងពីរនាក់ប្តីប្រពន្ធ។

ក៖ ហើយអញ្ចឹង ប្តីរបស់បងស្រីសព្វថ្ងៃគាត់ការអីដែរ បងស្រី?

ខ៖ គាត់ធ្វើសំណង់។

ក៖ ធ្វើសំណង់?

ខ៖ ចា៎! ស៊ីឈ្នួលគេមិនដែលបាននៅផ្ទះមួយថ្ងៃទេ។

ក៖ ហើយអញ្ចឹង តើបងស្រីធ្លាប់មានអនុស្សាវរីយ៍អីល្អៗជាមួយកូនទេ បងស្រី?

ខ៖ ធ្លាប់មានដែរ ថាមកទៅនាំកូនថា កូនអើយកូនឯងទៅរកស៊ីឆ្ងាយម៉ែនៅម្នាក់ឯងអញ្ចឹងទៅ ប្រាប់កូន ហើយកូនថា មិនអីទេម៉ែ ទៅត្រឹមថៃសោះតេរកគ្នាដល់សោះនឹង វាចេះនិយាយចឹងដែរ។

ក៖ ហ្នឹងហើយ!

ខ៖ ហើយថា អើយម៉ែចាស់ទៅគ្នាអ្នកណាចិញ្ចឹមទេ កូនស្រីទៅនៅខាងគេ ហើយកូនប្រុសនៅជាមួយនឹងគេមានប្រពន្ធទៅមិនដឹងទៅនៅណានៅណីក៏មិនដឹង ហើយគេថា ម៉ែឯងកុំភ័យពេកមើល ចាំដល់ពេលម៉ែឯងចាស់ទៅចាំគិតទៀត កូនវាថាចឹង។

ក៖ ហើយអញ្ចឹងសំរាប់បងស្រីចេះអាន និងសរសេរអក្សរខ្មែរទេ បងស្រី?

ខ៖ ខ្ញុំមិនសូវចេះដែរ ខ្ញុំអត់សូវចេះទេ គ្រាន់តែថាមើលដាច់តិចៗដែរ។

ក៖ មើលដាច់ដែរ តែមិនសូវច្បាស់។

ខ៖ មើលដាច់តិចតួចដែរ មិនច្បាស់ប៉ុន្មានទេ។

ក៖ ហើយអញ្ចឹងបងស្រីចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរ ទេបងស្រី?

ខ៖ អត់ចេះអីសោះតែម្តង ចេះតែភាសាខ្មែរ។

ក៖ ហើយអញ្ចឹងសំរាប់បងស្រីបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ បងស្រី?

ខ៖ ខ្ញុំរៀនដល់ថ្នាក់ទីបួន។

ក៖ បងស្រីរៀនដល់ថ្នាក់ទីបួន។

ខ៖ តែកាលជំនាន់នឹង បើសិនដូចជាក្មេងឥលូវខ្ញុំប្រហែលជាចេះអក្សរនឹងគេដែរយ៉ាង ប៉ុន្តែកាលនឹង ម៉ែរបស់ខ្ញុំគាត់ថា ខ្ញុំថា ម៉ែសុំលុយគាត់ចឹងទៅរៀន យើងគ្រួសារយើងវាគ្មាននោះ ខ្ញុំសុំថា ម៉ែសុំលុយមួយរៀល ម៉ែរបស់ខ្ញុំថា អត់មានទេ ហើយម៉ែខ្ញុំថា បើកូនឯងរៀនចាំតែមានលុយឈប់ទៅរៀនទៅ ហើយខ្ញុំឆោតអត់មានលុយអត់ទៅរៀន ហើយមួយរៀលសោះនឹងណាកាលនោះ ហើយម៉ែខ្ញុំគាត់គ្មាន គាត់មានលុយឯណាអោយកូនទៅរៀន រួចទៅបានឈប់ទៅរៀនទៅណាថ្នាក់ទីបួន ទៅសាលាគេមានលុយចាយ ខ្ញុំមិនដែលមានលុយចាយនឹងគេទេ សុំលុយម៉ែរបស់ខ្ញុំតែមួយរៀលគាត់មិនអោយព្រោះគាត់គ្មាន ហើយដល់ម៉ែរបស់ខ្ញុំគាត់ប្រាប់ថា បើគ្មានលុយទេ កូនឯងឈប់រៀនក៏ឈប់ចុះ ហើយខ្ញុំនឹងឈប់មែន ទ្រាំរៀនទាំងពីថ្នាក់ទីមួយដល់ថ្នាក់ទីបួននឹងគេហើយតើ មិនដែលមានលុយចាយនឹងគេទេទៅរៀននោះ។

ក៖ ហើយអញ្ចឹងសំរាប់បងស្រី កាលរៀននឹង តើរៀននៅសាលាណាដែរ បងស្រី?

ខ៖ រៀននៅសាលានឹង បឋមសិក្សាឃុំដំរិលដែរនឹង។

ក៖ អូ! សាលាបឋមសិក្សាឃុំដំរិលយើងនឹង!
ហើយអញ្ចឹងបងស្រីមានមិត្តភក្តិស្និតស្នាលដែលធំធាត់ មកជាមួយគ្នាទេ បងស្រី?

ខ៖ ខ្ញុំមិនដែលធ្លាប់មានទេ។

ក៖ អត់ដែលទេ បងស្រី!

ខ៖ ចាំ! មិនដែលធ្លាប់មានទេ ធ្លាប់មានតែដូចថាបងប្អូននៅក្នុងស្រុកក្នុងភូមិចឹង
ទៅរៀនអីជាមួយនឹងគ្នាចឹងដែលទៅណា ដូចបងប្អូនជីដូនមួយចឹង ធ្លាប់មានទៅរៀន
យើងទៅទាំងអស់គ្នាចឹងទៅ ចាំ! នឹងធ្លាប់មាន បើឆ្ងាយៗខ្ញុំមិនដែលមានទេ
ទល់តែនឹងឥលូវនឹង។

ក៖ ហើយអញ្ចឹងសំរាប់បងស្រីមានធ្វើស្រែចំការទេរាល់ថ្ងៃនឹង បងស្រី?

ខ៖ ខ្ញុំធ្វើ ធ្វើស្រែចំការដែរ។

ក៖ ធ្វើប៉ុន្មានដែរ បងស្រី?

ខ៖ ធ្វើដីបន្តិចនឹង ដីរបបដូចថា ឈ្មោះរបស់ខ្ញុំបានសាមសិបម៉ែត្រទៅ
ហើយឈ្មោះម្តាយរបស់ខ្ញុំបានសាមសិបម៉ែត្រទៅ ប៉ុននឹង។

ក៖ បានហុកសិបម៉ែត្រដែរ។

ខ៖ ចាំ! បានតែមួយរបរ មួយរបបនឹងណា គ្មានបានរកលុយទិញដីទិញអីផ្សេងៗអីនឹងគេទេ
ពិបាកណាស់ខ្ញុំនោះ។

ក៖ ហើយអញ្ចឹង ក្រៅពីធ្វើស្រែនឹង បងស្រីមានធ្វើការងារអីផ្សេងទៀតដើម្បីចិញ្ចឹមជីវិតទេ
បងស្រី?

ខ៖ គ្មានបានធ្វើការអីទេរាល់ថ្ងៃនេះយកតែថៅ។

ក៖ មើលតែថៅនឹង!

ខ៖ យកតែថៅអោយតែស្រួលខ្លួន វាមិនស្រួលទៀត មកអាហើមកនៅក្នុងបំពង់ក
លេបតែថ្នាំ ទៅតែពេទ្យ មិនដឹងជាយ៉ាងម៉េចទេ។

ក៖ ហើយអញ្ចឹងតាំងពីក្មេងរហូតមកដល់ពេលនេះ បងស្រីគិតថា
ជីវិតរបស់បងស្រីមានការផ្លាស់ប្តូរ ទេ បងស្រី?

ខ៖ ដូចជាគ្មានការផ្លាស់ប្តូរទេ។

កៈ នៅតែដដែលមែនទេ បងស្រី!

ខៈ អញ្ចេក! លោកគ្រូអើយបានថាអញ្ចឹង ពីមុននឹកឃើញថាចឹងដែរ បើសិនជាប្រឹងរកអោយមានបាននឹងគេទៅ លបានផ្ទះធំទ្រនំខ្ពស់នៅនឹងគេ នោះក៏មិនមើលផ្ទះខ្ញុំឃើញហើយនោះ ផ្ទះតូចជាងគេ តែផ្ទះភូមិមិនស្មើនឹងគេផង ឃើញហើយបើថាខ្ញុំភូតអី ដោយសារអី ដោយសារយើងអត់មានឪពុកម្ដាយអី ម៉ែរបស់គាត់ថ្លង់ទៀតហើយគាត់មិនសូវចំណាប់ចឹងណា ហើយងាកទៅខ្ញុំពីក្មេងមានឪពុកឯណានៅចិញ្ចឹមមើលថែបីបាច់ថែរក្សាអីដូចគេចឹងណា ខ្ញុំដឹងក្ដីឡើងខ្ញុំរកតែផ្ទះរនាតដេកមិនតាំងបានផង ពិបាកណាស់។

កៈ ហើយសំរាប់ម្ហូបវិញ តើបងស្រីចូលចិត្តហូបម្ហូបអីជាងគេ បងស្រី?

ខៈ ម្ហូបចូលចិត្តហូបជាងគេ សម្លម្ជូរគ្រឿង។

កៈ សម្លម្ជូរគ្រឿង!

ខៈ ចាំ! ចំណូលជាងគេ។

កៈ ហ្នឹងហើយ! ហ្នឹងហើយ! ហើយអញ្ចឹងសំរាប់ល្បែងប្រជាប្រិយខ្មែរយើងដូចជា បោះឈូង បោះអង្គញ់ ទាញព្រ័ត្រ បងស្រីមានចូលចិត្តលេងល្បែងអីទេ តាំងពីក្មេងមក?

ខៈ ធ្លាប់លេង ទៅលេងចូលឆ្នាំអី ទៅលេងអីស្វាដណ្ដើមស្លឹក លេងទាញព្រ័ត្រ ធ្លាប់ដែរ។

កៈ ហើយអញ្ចឹងសំរាប់បទចម្រៀងវិញ មានបទចម្រៀងណាដែលបងស្រីចូលចិត្តស្ដាប់ទេ បងស្រី?

ខៈ ខ្ញុំចូលចិត្តតែបទអី របៀបស្នេហាគ្នា បទអីគេហៅបទអី។

កៈ បទមនោសញ្ចេតនា។

ខៈ នោះហើយខ្ញុំចូលចិត្តតែបទចឹងចឹង ចូលចិត្តណាស់ រាល់ថ្ងៃក៏ចឹងដែរ បើបើកទូរទស្សន៍ទល់តែបទនោះបានស្ដាប់។

កៈ
ហើយអញ្ចឹងសំរាប់នៅក្នុងក្រុមគ្រួសាររបស់បងស្រីមាននរណាមួយដែលចេះលេងឧបករណ៍ភ្លេងទេ បងស្រី?

ខៈ អត់មានសោះម៉ង។

កៈ អត់មានសោះ!

ខៈ ចាំ! អត់មានសោះ។

កៈ ហើយអញ្ចឹងសំរាប់ផ្ទះរបស់បងស្រីមានលក្ខណៈដូចម្តេចដែរ តាំងពីក្មេងមកអញ្ចឹងណា តាំងនៅតូចៗ?

ខៈ ផ្ទះរបស់ខ្ញុំកាលនៅពីតូចៗ ផ្ទះខ្ញុំផ្ទះកាតាំងតូច។

កៈ ផ្ទះទាម ឬក៏?

ខៈ ផ្ទះខ្ពស់ដែរ តាំងពីខ្ញុំដឹងក្តីមកផ្ទះខ្ពស់ដែរ កាំជណ្តើរប៉ុន្មានកាំទេ។ ហ្នឹងហើយ! រួចទៅរហេក រហាក អើយ មិនសមជាផ្ទះទេ។

កៈ ហើយអញ្ចឹង ផ្ទះតូចនឹងនរណាគេជាអ្នកធ្វើឡើងដែរ បងស្រី?

ខៈ ម៉ែរបស់ខ្ញុំ ពុករបស់ខ្ញុំនឹងណា។

កៈ អូ! ម្តាយឪពុកគាត់ជាអ្នកធ្វើ។
ហើយអញ្ចឹងសំរាប់ផ្ទះនឹងគាត់បានសំភារៈមកពីណាសំរាប់ធ្វើដែរ បងស្រី?

ខៈ ទេ ខ្ញុំមិនដឹងដែរ ស្រាប់តែខ្ញុំដឹងក្តីឡើងខ្ញុំឃើញផ្ទះនឹងទ្រេតទ្រោតទៅហើយ មិនតាំងមានរនាតរនូតដេកផងស្រួលបួលផងឃើញនឹងនោះ។

កៈ ហ្នឹងហើយ!
ខៈ កាលខ្ញុំឃើញកាលនោះ ថាពិបាកណាប្រវត្តិរបស់ខ្ញុំពិបាកណាស់។

កៈ អញ្ចឹងពេលបងស្រីកើតមកបងឃើញផ្ទះនឹងហើយ អត់ដឹងបានមកពីណាធ្វើទេ ន់បងន់! អញ្ចឹង នរណាគេជាអ្នកជួយបង្រៀនគាត់អោយធ្វើផ្ទះមួយនឹងដែរ បងស្រី?

ខៈ ខ្ញុំធ្លាប់លឺពុករបស់ខ្ញុំគាត់មកគាត់និយាយថា ផ្ទះនឹងគាត់អ្នកធ្វើចឹងណា។ ចាំ! ខ្ញុំធ្លាប់លឺគាត់និយាយតែត្រង់មែនមិនមែនខ្ញុំមិនដឹងដែរ កាលនោះគាត់ថា កាលដែលគាត់នៅយកម្តាយរបស់ខ្ញុំ គាត់ធ្វើផ្ទះនឹងទុកអោយកូននៅចឹង គាត់ថាចឹងដែរ។

កៈ ហើយអញ្ចឹងសំរាប់បងស្រីមានជំនាញដែលបន្តវេនពីក្រុមគ្រួសារដូចជា វេញវល្លិ៍ផ្តៅ ឬក៏ជំនាញធ្វើស្ករត្នោតអីទេ បងស្រី?

ខៈ ខ្ញុំអត់ចេះអីទេ។

កៈ អត់ចេះទេ!

ខ៖ ខ្ញុំអត់ចេះទេ តែដេរប៉ះនឹងមិនសូវចេះនឹងគេផង។

ក៖ ហើយអញ្ចឹងសំរាប់បងស្រីមានបានឆ្លងកាត់សម័យសង្គ្រាមទេ បងស្រី?

ខ៖ ខ្ញុំនៅតូច ដូចខ្ញុំនិយាយម៉េចចឹង ខ្ញុំទើបបានកន្លះខែកើតសម័យសង្គ្រាមនឹងនោះ ខ្ញុំបានកន្លះខែ កើតហើយបានកន្លះខែបានសង្គ្រាមកើតឡើង ដល់អញ្ចឹងខ្ញុំអត់ដឹងទេ ដល់ពេលខ្ញុំទើបលឺម្ដាយរបស់ខ្ញុំគាត់មកពីកៀរវិញផុតពីសម័យសង្គ្រាមមកវិញគាត់និយាយប្រាប់ គាត់និយាយតាំងពីខ្ញុំបានកូនមួយ គាត់និយាយគាត់ពិបាកចឹងទៅគាត់ចេះតែនិយាយប្រាប់យើងអោយយើងដឹងខ្លះៗចឹងទៅណា តែបើសិនជាគាត់និយាយក៏មិនអស់សាច់រឿងគាត់ដែរ។ លឺគាត់និយាយប្រវត្តិរបស់គាត់ បើសិនជាខ្ញុំវិញ ចប់ហើយ ប៉ុន្តែគាត់តស៊ូបាននៅរស់ដល់ចិតសិបឆ្នាំជាងគាត់អាយុចិតជាងហើយលោកគ្រូ ដល់តែឥលូវនឹងគាត់តស៊ូពិបាកលំបិនជាមួយកូនចៅមកឆ្អែតឆ្អន់ទៀត បើជីវភាពគាត់ក្រពិបាកវេទនា។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីងមានពេលលំបាកនៅក្នុងជីវិតទេ អ្នកមីង?

ខ៖ មាន។

ក៖ លំបាកជាងគេ ពេលណាដែរ បងស្រី?

ខ៖ ពេលកូនខ្ចីម្ដងៗអត់មានលុយអត់មានកាក់។ កាលឆ្នាំខ្ញុំកើតកូនមីបង ខ្ញុំគ្មានលុយមួយលុយខ្មែរទេ ប៉ុន្តែខ្ញុំមានប្ដីអីនៅ គាត់ដូចថាគាត់ចេះដឹងចឹងដែរណា ជួយយើងដែរ តែក្នុងខ្លួនឯងនឹងគ្មានលុយទេ បើសិនកើត កាលដែលខ្ញុំឆ្លងទន្លេបើសិនជាមានលុយដូចសព្វថ្ងៃអត់កើតនៅផ្ទះទេ ប្រហែលជាទៅរកពេទ្យរកម៉ូនឹងគេហើយ ហើយខ្ញុំកើតកូនទីមួយទីពីរអត់ដែលបានទៅដល់ពេទ្យទេ កើតនៅ ដូចថាពេទ្យឆ្មប់នៅផ្ទះចឹងណា ហើយវេទនាណាស់ វេទនាដោយសារយើងបានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹកចឹងណា វាមិនមានស៊ីគ្រប់គ្រាន់ដូចគេដូចឯងចឹង។

ក៖ ហើយអញ្ចឹងសំរាប់បងស្រីធ្លាប់មានបទពិសោធន៍ល្អៗនៅក្នុងជីវិតទេដូចជា អាពាហ៍ពិពាហ៍កូនចៅ ឬក៏បុណ្យទានអីចឹង?

ខ៖ បើបុណ្យទានខ្ញុំអត់ធ្លាប់បានធ្វើទេ តែបើអាពាហ៍ពិពាហ៍កូនចៅធ្លាប់បានធ្វើហើយ។ ទៅដូចថា ពេលនោះដូចថាមានអារម្មណ៍ថាសប្បាយចិត្តដែរ បានការកូនបានអីចឹង

សប្បាយចិត្តដូចថាយើងថតរូបជាមួយកូន ជាមួយកូនប្រសារ
ជាមួយប្ដីប្រពន្ធក្រុមគ្រួសារយើងចឹង ធ្លាប់មានដែរ។

ក៖ ហើយអញ្ចឹងសំរាប់បងស្រីពេលនៅក្មេងៗ
បងស្រីធ្លាប់មានក្ដីសង្ឃឹមថាពេលធំឡើងបងស្រីចង់ធ្វើអ្វីមួយទេ បងស្រី?

ខ៖ ធ្លាប់ដែរ ធ្លាប់ថាបើសិនជាធំឡើង ចង់ថាបើសិនរៀន រៀនអោយចេះកុំអោយពិបាក
តែជៀសមិនរួចអារឿងពិបាកនឹងម៉ង។

ក៖ នៅតែពិបាក!

ខ៖ ហ្នឹងហើយ! នៅតែពិបាកដដែល ធ្លាប់គិត ដល់ឥលូវប្រាប់កូនប្រាប់ចៅថា
អោយប្រឹងរៀនទៅកុំអោយពិបាកដូចម៉ែ ដល់កូននឹងវាមិនចង់រៀនទៀតណា
វាអត់ចង់រៀនទេ ថាកូនឯងចាំមើលមិន  ស្ដាយខ្លួនដូចម៉ែ
ម៉ែស្ដាយខ្លួនខកខ្លួនទល់តែថ្ងៃនេះហើយ ស្ដាយខ្លួនដោយសារអី ដោយសារមិនចេះ
ដល់ពេលយើងមិនចេះយើងទៅណាក៏មិនរួច ដូចចឹងនៅចឹង នឹងដោយសារមិនចេះ
ហើយដល់កូននឹងរាល់ថ្ងៃដូចជួលចឹង សព្វថ្ងៃដូចជួលថាអោយកូនទៅរៀន
ថាអោយតែកូនថាម៉េច អោយក៏មិន សុខចិត្តអត់ក្នុងខ្លួនអោយតែកូនបានទៅសាលា។

ក៖ ព្រោះយើងដឹងថា ពេលយើងអត់ចេះយើងពិបាក។ ហ្នឹងហើយ!
បើសិនជាបងស្រីចង់ផ្ដាំផ្ញើរអ្វីមួយទៅកាន់កូនចៅជំនាន់ក្រោយ
បងស្រីចង់ផ្ដាំផ្ញើរប្រាប់ពួកគេអ្វីខ្លះ បងស្រី?

ខ៖ ខ្ញុំចង់ផ្ដាំផ្ញើរថា
សូមកូនចៅទាំងអស់អោយប្រឹងរៀនសូត្រកុំអោយល្ងង់ខ្លៅដូចខ្ញុំចឹងពិបាកណាស់
មិនមែនស្រួលទេដើររកស៊ីទៅណាមកណាមិនចេះអក្សរគឺពិបាកណាស់។
សូមអោយកូនចៅប្រឹងរៀនប្រឹងសូត្រទាំងអស់គ្នានឹងទៅ
អោយស្រណុកចេះទៅយើងទៅរកការងារអីក៏បានដែរ ន់លោកគ្រូ។

ក៖ ហើយអញ្ចឹង
បើសិនជាបងស្រីចង់អោយកូនចៅរបស់បងស្រីជៀសវាងចង់អោយគាត់ជៀសវាងពីអ្វីខ្លះ
បងស្រី?

ខ៖ សូមជូនពរអោយកូនចៅជៀសវាងអារឿងគ្រឿងញៀននឹងកុំអោយទៅបៀតបៀនអី
អាគ្រឿងញៀននឹងជៀសអោយផុត កុំអោយគ្រឿងញៀននឹងវាមិនស្រួលទេ។

ក៖
ហើយអញ្ចឹងចុងក្រោយសូមអរគុណច្រើនបងស្រីសំរាប់ពេលវេលារបស់បងស្រីអោយខ្ញុំ
សម្ភាសន៍ពីជីវិតរបស់បងស្រី ហើយអញ្ចឹងចុងក្រោយសូមជូនពរបងស្រីមានសុខភាពល្អ
មានកំលាំងមាំមួន មានប្រាជ្ញាវៀងវៃ ហើយសូមអោយកូនចៅរបស់បងស្រីមានសុខភាពល្អ
មានកំលាំង មានប្រាជ្ញាវៀងវៃផងដែរណាបងស្រី
ហើយថាគាត់ប្រកបមុខរបររកស៊ីអីចេះតែជោគជ័យចឹងណា
ដើម្បីគាត់អាចជួយដល់បងស្រីមានជីវភាពល្អប្រសើរជាងរាល់ថ្ងៃនឹងណាបងស្រី។
អរគុណច្រើន បងស្រី។